

## ជំពូកទី ១៣

# ការក្លាយជាចំណែករបស់សហគមន៍

កុមារដែលមិនអាចមើលឃើញច្បាស់ គឺជាចំណែកនៃសហគមន៍ដូចកុមារដទៃទៀតអញ្ចឹងដែរ ។ ប៉ុន្តែញឹកញាប់ណាស់ កុមារដែលមិនអាចមើលឃើញច្បាស់ត្រូវបានទុកចោលនៅផ្ទះ ។ ពួកគេកម្របានចេញទៅលេងនៅខាងក្រៅ ឬ ដើរទៅនេះទៅនោះ ឬ ជួយធ្វើកិច្ចការរបស់ក្រុមគ្រួសារ ។ កុមារទាំងនេះមានឱកាសតិចតួចណាស់ក្នុងការទាក់ទងឱ្យបានស្គាល់មនុស្សឯទៀត ហើយមនុស្សឯទៀតក៏មិនបានទាក់ទងឱ្យបានស្គាល់កុមារទាំងនេះឡើយ ។ មនុស្សម្នាទំនងជាគិតថា កុមារពិការភ្នែកមិនអាចរៀនពីរបៀបធ្វើអ្វីមួយបានឡើយ ។ នៅពេលកុមារដែលមិនអាចមើលឃើញច្បាស់ចេញដើរនៅក្នុងសហគមន៍ មនុស្សម្នាតែងស្ទាក់ស្ទើរចិត្តក្នុងការនិយាយទៅរក ឬ មិនដឹងការរៀបចំបួកពារជាមួយពួកគេយ៉ាងណាឡើយ ។




ក្នុងនាមជាឪពុកម្តាយ អ្នកអាចធ្វើអ្វីៗបានយ៉ាងច្រើនដើម្បីជួយកូនអ្នកឱ្យក្លាយជាសមាជិកសកម្មនៃសហគមន៍ ។ ចូរនាំកូនទៅជាមួយឱ្យបានញឹកញាប់តាមដែលអាចធ្វើបានដូចជា នៅពេលអ្នកទៅដងទឹក ឬ ទៅរកអុស, ពេលអ្នកទៅផ្សារ, ឬ ទៅសាលារៀន, ទៅកន្លែងបុណ្យទាន និងពិធីប្រជុំនៅក្នុងសហគមន៍ ព្រមទាំងចូលរួមក្នុងព្រឹត្តិការណ៍ទាំងឡាយ ។ នៅតាមផ្លូវ ចូររៀបរាប់ប្រាប់កូនពីអ្វីដែលអ្នកឃើញ និងលើកទឹកចិត្តនាងឱ្យស្តាប់សម្លេងនានា និងប៉ះ ហើយហិតក្លិនអ្វីៗ ។ ចូរណែនាំនាងដល់មនុស្ស និងសត្វដែលអ្នកបានជួប ព្រមទាំងបង្រៀននាងពីរបៀបគួរសមដល់មនុស្សម្នាទាំងឡាយ ។

## របៀបដែលសមាជិកសហគមន៍អាចជួយយកអាសារ

សមាជិកសហគមន៍អាចស្វែងសិក្សាឱ្យដឹងថា កុមារដែលមិនអាចមើលឃើញច្បាស់ គឺសកម្មដូចកុមារដទៃអញ្ចឹងដែរ ។ តែនាងក៏ត្រូវការការជួយពិសេសដើម្បីឱ្យបានស្គាល់មនុស្សម្នា និងស្វែងរកផ្លូវដើរចេញចូលដោយខ្លួនឯងផងដែរ ។ មនុស្សម្នាអាចទើសទាល់ចិត្តជាមួយកូនរបស់អ្នក ទាល់តែអ្នកពន្យល់អ្នកទាំងនោះពីរបៀបរៀបចំឫកពារជាមួយនាង ។

### ➤ វិធីជួយសមាជិកសហគមន៍ឱ្យចេះទាក់ទងជាមួយកូនរបស់អ្នក

ចូរលើកទឹកចិត្តសមាជិកសហគមន៍ឱ្យនិយាយរកកូនរបស់អ្នកនៅពេលណាពួកគាត់ជួបនាង ។ ស្នើឱ្យពួកគាត់ណែនាំខ្លួនដល់កូនរបស់អ្នក និងហៅនាងឱ្យចំឈ្មោះ ដូច្នេះនាងដឹងថាពួកគាត់និយាយរកនាង ។ ចូរពន្យល់ថាពួកគាត់គួរតែនិយាយត្រង់ទៅរកនាងជាជាងសួរអ្នកដទៃអំពីនាង ។




ចូរលើកទឹកចិត្តមនុស្សម្នាឱ្យជួយកូនអ្នកស្វែងរកអ្វីដែលនាងកំពុងរក ។ សមាជិកសហគមន៍ក៏អាចរៀនផងដែរ ដើម្បីប្រាប់ទិសដៅដែលនឹងជួយនាងឱ្យរកអ្វីៗដោយខ្លួននាងផ្ទាល់( សូមអានទំព័រ 111 ដល់ 113) ។







ចូរលើកទឹកចិត្តមនុស្សម្នាឱ្យឆ្លើយតបនឹងសំណួរកូនអ្នក ហើយពន្យល់ពីអ្វីៗដល់នាង ។ ខណៈពេលដែលសមាជិកសហគមន៍ចាប់ស្គាល់កូនអ្នក ពួកគាត់នឹងចាប់ផ្តើមដឹងថានាងអាចធ្វើអ្វីៗបានច្រើនជាងការគិតទុករបស់ពួកគាត់ថាអាចទៅរួច ។

## របៀបដែលកុមារឯទៀតៗអាចជួយយកអាសារ

ក្មេងៗអាចគ្មានចិត្តធម៌មេត្តាចំពោះកុមារដែលមិនអាចមើលឃើញច្បាស់ ។ ពួកគេអាចបន្ទុះបង្អាប់, សើចចំអក, ធ្វើត្រាប់តាម ឬ វាយធ្វើបាបកុមារពិការភ្នែកក៏មានដែរ ។ តែជាញឹកញាប់ពួកគេគ្មានចិត្តសណ្ដោសប្រណីយ៉ាងសាមញ្ញ ដោយទុកកុមារដែលមិនអាចមើលឃើញច្បាស់ឱ្យនៅក្រៅការលេងកំសាន្ត ឬ សកម្មភាពនានារបស់ពួកគេ ។

**➤ វិធីជួយក្មេងៗឱ្យយល់ថា តើការមើលមិនឃើញនោះយ៉ាងដូចម្ដេច?**

ជារឿយៗកុមារបញ្ចេញបូកពារមិនសណ្ដោសប្រណី ពីព្រោះពួកគេខ្លាចនូវអ្វីដែលពួកគេមិនយល់ ។ នៅពេលពួកគេយល់ កុមារអាចក្លាយជាអ្នកជួយដល់ក្មេងម្នាក់ទៀត ឬ ជាមិត្តភក្តិ ។ នេះជាល្បែងកំសាន្តមួយចំនួនដែលអាចជួយក្មេងឱ្យយល់អំពីភាពពិការភ្នែក :-

**ល្បែងកំសាន្ត : ស្រទាំងភ្នែក**

ក្មេងអាចស្វែងរកឱ្យឃើញថា តើការមើលមិនឃើញនោះវាមានសភាពយ៉ាងណា បើសិនជាពួកគេ :-



**ពាក់វ៉ែនតាធុនក្រាស់របស់នរណាម្នាក់ ឬ វ៉ែនតាការពារពន្លឺថ្ងៃដែលចាស់ មានស្នាមកោសឆូតឆ្វាត់ឆ្វែង។**



**គ្របមុខពួកគេជាមួយនឹងក្រដាសស្ដើងមួយផ្ទាំង ឬ សម្ភារៈដទៃទៀតដែលអាចឱ្យពួកគេមើលឃើញយ៉ាងតិចបំផុត។**




បន្ទាប់មកឱ្យក្មេងៗសាកល្បងមើលអ្វីមួយដែលតូចល្អិតដូចជា ផ្ទៃសំណាញ់លើស្លឹកឈើ ឬ អក្សរតូចល្អិតលើកំប៉ុងដែក ។ ស្នើឱ្យក្មេងៗប្រាប់ថាពួកគេមានអារម្មណ៍បែបណាក្នុងការសាកល្បងមើលរបស់របរទាំងនេះ ។ តើពួកគេដាក់វត្ថុទាំងនេះជិតប៉ុណ្ណាដើម្បីអាចឱ្យភ្នែកពួកគេមើលឃើញច្បាស់ល្អ?

**ល្បែងកំសាន្ត : ការនាំផ្លូវកុមារពិការភ្នែក**



ឱ្យកុមារចាប់គូគ្នា ។ ចូរយកក្រមាចងជុំវិញភ្នែករបស់កុមារម្នាក់ ធ្វើដូច្នេះនាងមិនអាចមើលឃើញអ្វីទាល់តែសោះ ហើយឱ្យក្មេងម្នាក់ទៀតធ្វើជាអ្នកនាំផ្លូវនាង ។ អ្នកនាំផ្លូវត្រូវនាំបុគ្គល "មើលមិនឃើញ" ដើរ ហើយឱ្យនាងស្ទាបវត្ថុប្លែកៗគ្នា និងនាំនាងដើរដោយសុវត្ថិភាព ។ ក្រោយពេលលេងល្បែង ចូរលើកទឹកចិត្តក្មេងឱ្យនិយាយអំពីសំណួរទាំងនេះ :-

- នៅពេលមើលមិនឃើញ តើពួកគេមានអារម្មណ៍យ៉ាងណា ?
- តើពួកគេខ្លាចឬទេ?
- តើអ្នកនាំផ្លូវបានធ្វើអ្វីខ្លះ ដែលមានប្រយោជន៍ និងគ្មានប្រយោជន៍?
- តើអ្នកនាំផ្លូវគួរធ្វើអ្វីដែលគ្រាន់បើជាងនេះ?
- តើអ្នកទុកចិត្តអ្នកនាំផ្លូវរបស់អ្នកឬទេ?

**ល្បែងកំសាន្ត : ស្ទាបមិត្តភក្តិ**



យកកំណាត់ចងជុំវិញភ្នែករបស់ក្មេងម្នាក់ ធ្វើដូច្នេះនាងមិនអាចមើលឃើញអ្វីទាល់តែសោះ ។ បន្ទាប់មកឱ្យនាងសាកល្បង ចំណាំមិត្តភក្តិនាងដោយការស្ទាបពួកគេ ឬ នាងអាចសាកល្បងចំណាំវត្ថុខុសៗគ្នាតាមរយៈការស្ទាប ។ បន្ទាប់មកពិភាក្សាគ្នាអំពី ថាតើការមិនអាចមើលឃើញនោះវាយ៉ាងណា ។

**ល្បែងកំសាន្ត : នោះជាក្លិនអ្វី?**




ចូរយកកំណាត់ចងជុំវិញភ្នែកកុមារមួយក្រុម ធ្វើដូច្នេះពួកគេមិនអាចមើលឃើញអ្វីទាល់តែសោះ ។ បន្ទាប់មកយករបស់អ្វីមួយ ដែលមានក្លិនឆ្អួលខ្លាំង ដាក់ចំពីមុខក្មេងម្នាក់ៗដូចជា សំបកក្រូចពោធិ៍សាត់, ស្លឹកតែ, កាហ្វេគ្រាប់, ចេក ឬ ដំណាំក្នុងភូមិ ។ ចូរសង្កេតមើលបើសិនជាកុមារអាចស្គាល់វត្ថុទាំងនេះដោយក្លិនរបស់វា ។

ក្រោយពីកុមារលេងល្បែងទាំងនេះហើយ ចូរពន្យល់ពួកគេថា ជាធម្មតាវិញ្ញាណនៃការស្ទាប ឬ ប៉ះ, ការហិតក្លិន, និងការភ្លក់រសជាតិរបស់មនុស្សពិការភ្នែកនឹងកាន់តែពូកែឡើង ដោយសារពួកគេមិនអាចមើលឃើញ ។

**➤ វិធីជួយក្មេងៗឱ្យបញ្ចូលកុមារដែលមិនអាចមើលឃើញទៅក្នុងល្បែងកំសាន្តរបស់ពួកគេ**

ជារឿយៗក្មេងមិនបានដឹងថាកុមារដែលមិនអាចមើលឃើញច្បាស់អាចលេងកំសាន្តជាមួយពួកគេ បើសិនជាពួកគេកែប្រែល្បែងកំសាន្តនោះបន្តិចបន្តួច ។ ឧទាហរណ៍ :-












**នៅពេលនាងអាចស្តាប់ឮសម្លេងបាល់ វីណាអាចចូលរួមក្នុងល្បែងកំសាន្តនេះ។**

នេះជាយោបល់មួយចំនួនទៀតសំរាប់ការដាក់បញ្ចូលកុមារដែលមិនអាចមើលឃើញច្បាស់ក្នុងល្បែងកំសាន្ត :-



យកស្បោងមួយ ហើយដាក់គ្រាប់សណ្តែក ឬ ច្រកអង្ករឱ្យពេញក្នុងស្បោង បែបនេះក៏អាចប្រើជំនួសបាល់ក្នុងល្បែងកំសាន្តបោះបាល់បានដែរ ។ ស្បោងនឹងបញ្ចេញសូរសម្លេងនៅពេលបោះ និងពេលវាធ្លាក់ប៉ះដី ឬ សាកល្បងលេង "ចាប់" ដោយការរមៀលបាល់នៅលើដី ឬ ផ្ទៃរាបស្មើ ។ កុមារអាចស្តាប់ឮបាល់នៅពេលវារមៀល និងចាប់វា ។

**បើកុមារអាចមើលឃើញពណ៌ភ្លឺ ចូរប្រើស្បោង ឬ កំណាត់ដែលមានពណ៌ភ្លឺ។**

កុមារដែលមិនអាចមើលឃើញច្បាស់អាចចូលរួមល្បែងលេងដេញចាប់ បើសិនជាក្មេងៗទះដៃរបស់ខ្លួន ឬក៏ហួចនៅពេលពួកគេរត់ ឬ មានអ្វីមួយចងជាប់នឹងខ្លួនពួកគេ ដើម្បីធ្វើឱ្យឮសម្លេងជាសញ្ញាដល់កុមារដែលមិនអាចមើលឃើញច្បាស់ ។



កុមារដែលមិនអាចមើលឃើញច្បាស់អាចលេងលោតអន្ទាក់ បើសិនជាមានកណ្តឹងចងជាប់នឹងខ្សែអន្ទាក់ ។



កុមារតូចអាចប្រើកំប៉ុងសំរាប់ធ្វើជា ស្គរ, ប្រដាប់ក្រឡុកធ្វើពីកំប៉ុងដែកហើយដាក់ដុំថ្មតូចៗចូល ឬ គម្របដបដោតខ្សែជាចង្កោម ដើម្បីធ្វើជាប្រភេទឧបករណ៍តន្ត្រីខុសៗគ្នា ( សូមអានទំព័រ 185 ) ។



ការគូររូបលើដីខ្សាច់សើម ឬ លើភក់ ជួយឱ្យកុមារស្ទាបដឹងពីរូបអ្វីមួយដែលនាងបានគូរ ។



កុមារដែលមិនអាចមើលឃើញច្បាស់អាចរត់ប្រណាំងដោយប្រើខ្សែចងរវាងដើមឈើពីរ បែបនេះ :-



**ចងចុងខ្សែម្ខាងជាប់ទៅដើមឈើមួយ។ បន្ទាប់មកលើខ្សែដដែលនោះ ចូរគួចចំណងធំមួយក្នុងប្រវែង 1 ឬ 2 ម៉ែត្រពីដើមឈើទីមួយ។**



**ចូរសិកចុងខ្សែចូលតាមបំពង់ដូចជា បំពង់ឫស្សីមួយកង់ខ្លី ។**



**ចូរគួចចំណងធំមួយទៀតនៅប្រវែង 1 ឬ 2 ម៉ែត្រពីដើមឈើទីពីរ។ បន្ទាប់មកចងកន្ទុយខ្សែជុំវិញដើមឈើទីពីរ។ ត្រូវធ្វើយ៉ាងណាកុំឱ្យបំពង់ឫស្សីចេញរួចពីចំណងគួច។**

ចំពោះគំនិតបន្ថែមទៀត ឱ្យកុមារនៅក្នុងសហគមន៍ប្រាប់ដល់អ្នក ។ ចាំមើលថាតើនរណាអាចលើកឡើងនូវគំនិតដែលលេចធ្លោបំផុតនៃរបៀបដាក់បញ្ចូលកុមារដែលមិនអាចមើលឃើញច្បាស់ទៅក្នុងល្បែងកំសាន្តរបស់ក្មេងៗ ។

## គម្រោងនៃសហគមន៍

ការសាងសង់សួនលេងកំសាន្តរបស់កុមារ គឺជាសកម្មភាពដែលអាចជួយកុមារ និងសមាជិកសហគមន៏រៀនធ្វើការរួមគ្នា ហើយមានអ្វីៗយ៉ាងសាមញ្ញមួយចំនួនដែលអាចធ្វើឱ្យសួនលេងកំសាន្ត ក្លាយជាកន្លែងកំសាន្តសប្បាយសំរាប់កុមារគ្រប់រូប ។ ពេលនោះកុមារដែលមិនអាចមើលឃើញច្បាស់ លែងមានអារម្មណ៏នៅដាច់ឡែកពីគេឯង ។ កុមារគ្រប់រូបនៅក្នុងសហគមន៏នឹងបានរីករាយជាមួយគំនិតដែលបានផ្តល់នៅទីនេះ ។




## ការសាងសង់សួនលេងកំសាន្តសំរាប់កុមារ

ជាការប្រសើរបំផុត ការប្រើសម្ភារៈក្នុងស្រុកដែលមានតម្លៃថោក ហើយងាយស្រួលក្នុងការសាងសង់សួនលេងកំសាន្ត ។ សួនលេងកំសាន្តនឹងផ្តល់ឱ្យកុមារ និងឪពុកម្តាយមានឱកាសដើម្បីសាកល្បងការលេងកំសាន្តអ្វីមួយដែលប្លែកៗ ។ ក្រោយមកទៀត ឪពុកម្តាយអាចសាងសង់នៅផ្ទះរបស់ខ្លួននូវអ្វីដែលអាចឱ្យកូនរបស់គាត់លេងកំសាន្តដោយតម្លៃថោក ឬមិនចំណាយលុយ ។ ចំពោះហេតុផលនេះ សួនលេងកំសាន្តសំរាប់កុមារអាចសាងសង់ពីមែកឈើ និងបង្គោលឈើវែងៗ សំបកកង់ឡានចាស់ៗ និងសម្ភារៈ "សំណល់ដែលគេបោះចោល" គឺវាគ្រាន់បើជាងសួនលេងកំសាន្តដែលហ៊ឺហា និងផលិតពីដែកថ្លៃ ហើយចំណាយអស់ដើមទុនច្រើន ។

## សួនលេងកំសាន្តសំរាប់កុមារគ្រប់រូប

**រីបារ៉ាល់តា**ជាក្រុងមួយនៅដាច់ស្រយាលក្នុងប្រទេស**បូលីវា**។ ដោយសារផ្លូវខូច ការធ្វើដំណើរតាមរថយន្តពីក្រុង**រីបារ៉ាល់តា** ទៅទីក្រុងដែលនៅជិតវាបំផុតត្រូវចំណាយពេល 30 ម៉ោង។ **រីបារ៉ាល់តា**ជាក្រុងក្រីក្រមួយដែលគ្មានប្រព័ន្ធទឹកឡើយ ហើយប្រជាជនជាច្រើនរស់នៅក្នុងក្រុងនេះគ្មានភ្លើងអគ្គិសនីប្រើប្រាស់។ ឳពុកម្ដាយដែលមានកូនពិការមួយក្រុមបានចាប់ផ្ដើមធ្វើការប្រជុំរៀងរាល់ 2 សប្ដាហ៍ម្ដង។ ពួកគាត់បានដឹងថាក្រុមរបស់គាត់ក្លាយជាអ្នកជំនាញអំពីតម្រូវការកូនៗរបស់ពួកគាត់។

ពួកគាត់ចង់ធ្វើការអប់រំសហគមន៍អំពីកុមារពិការ ដោយសារពួកគាត់បានដឹងយ៉ាងច្រើនអំពីពិការភាព។ ពួកគាត់បានសំរេចចិត្តសាងសង់ "សួនលេងកំសាន្តសំរាប់កុមារគ្រប់រូប" មួយកន្លែង ដើម្បីឱ្យកុមារពិការនិងកុមារមិនពិការមកជួបជុំគ្នាតាមរយៈការលេងកំសាន្ត។

គំនិតដំបូងរបស់ក្រុមឳពុកម្ដាយបានគិតថា គម្រោងនេះត្រូវចំណាយពេលអស់តែ 3 ថ្ងៃនោះ បានក្លាយទៅគម្រោងមួយធំជាងការគិតរបស់ពួកគាត់ នៅពេលដែលមនុស្សម្នាចាប់ផ្ដើមរិះគិតរកគំនិតកាន់តែច្រើនសំរាប់សួនលេងកំសាន្ត។ ពួកគាត់បានទទួលការបរិច្ចាគពីក្រុមហ៊ុន និងចំការនានាដែលបានផ្ដល់ដុំឥដ្ឋ, ដែកគោល, ឈើ, និងដើមឈើ។ សួនលេងកំសាន្តបានបញ្ចប់រួមមាន របង, កៅអីវែងសំរាប់អង្គុយលេង, ដើមឈើ, ហើយមានបំពាក់ឧបករណ៍ទាំងឡាយសំរាប់កន្លែងលេងកំសាន្តរបស់កុមារដែលធ្វើពីឈើក្នុងស្រុក និងសំបកកង់ឡានចាស់ៗ។

ក្មេងៗរីករាយវារលេងតាមប្រហោងធុងសាំង ឬស្គរចាស់ៗដែលលាងសំអាតហើយ។ កុមារពិការភ្នែកនឹងរីករាយធ្វើសម្លេងពួកគេឱ្យខ្ទរនៅក្នុងស្គរ។

សាកល្បងដាក់បញ្ចូលប្រភេទទោងខុសៗពីគ្នា។ ធ្វើទោងខ្លះទាបល្មមសំរាប់ឱ្យកុមារតូចៗឈោងដល់ដោយខ្លួនឯង។



កុមារដែលមិនអាចមើលឃើញច្បាស់នឹងអាចរកអ្វីៗឃើញ ហើយអាចប្រើឧបករណ៍លេងកំសាន្ត បើសិនជាឧបករណ៍ទាំងនោះត្រូវបានលាបពណ៌ភ្លឺច្បាស់។ កុមាពិការភ្នែកនឹងអាចរកឃើញផ្លូវនៅជុំវិញ បើសិនជាចិញ្ចើមផ្លូវមានគែម ហើយកន្លែងខ្លះមានស្មៅ និងកន្លែងខ្លះទៀតគ្មានស្មៅ។

ក្មេងៗចូលចិត្តធ្វើសម្លេងដោយគោះ, ទះ ឬ វាយរបស់របរ។ ជាពិសេសកុមារពិការភ្នែកចូលចិត្តលេងល្បែងប្រភេទនេះ។

## ការផ្ដល់យោបល់ចំពោះសួនលេងកំសាន្តសំរាប់កុមារគ្រប់រូប

- ទាក់ទាញមនុស្សជាច្រើននៅក្នុងសហគមន៍ឱ្យចូលរួមបានច្រើនតាមដែលអាចធ្វើបាន នៅក្នុងការសាងសង់ និងថែទាំសួនលេងកំសាន្តសំរាប់កុមារ ។ សួនលេងកំសាន្តត្រូវតែសំអាត និងជួសជុលឱ្យបានទៀងទាត់ ហើយត្រូវការធ្វើផែនការនិងការរៀបចំ ។

- សួនលេងកំសាន្តសំរាប់កុមារត្រូវរៀបចំឱ្យសាមញ្ញ និងសាងសង់ពីសម្ភារៈក្នុងស្រុកមានតម្លៃថោក ។ តាមវិធីនេះ មនុស្សម្នាអាចចម្លងគំនិតតាមគំរូនេះ និងសាងសង់ឧបករណ៍សំរាប់កូនរបស់ពួកគាត់នៅផ្ទះរបស់ខ្លួន ។

- សំរាប់បង្គោលឈើវែងៗដែលត្រូវដាំទៅក្នុងដី ចូរប្រើប្រភេទឈើដែលមិនងាយពុកឆាប់ពេក ។ ចូរលាបចុងបង្គោលដែលដាំបញ្ចូលទៅក្នុងដីជាមួយប្រេងម៉ាស៊ីន, ជ័រ ឬ ថ្នាំកំចាត់សត្វល្អិត ឬ ថ្នាំការពារកុំឱ្យផ្សិតដុះជាប់បង្គោល ។

- ទោងអាចចងព្យួរពីខ្សែពួរ ឬ ច្រវ៉ាក់ ។ ខ្សែពួរគឺថោកជាង តែអាចផុយ ឬ ឆាប់ខូចបំផុត ។ ខ្សែនីឡុង ឬ ប្លាស្ទិកមិនងាយផុយពេលត្រូវភ្លៀង តែវាងាយស្រួយនៅក្រោមកំដៅថ្ងៃ ។

- ចូរពិនិត្យភាពរឹងមាំរបស់បង្គោល និងខ្សែឱ្យបានញឹកញាប់ដោយឱ្យមនុស្សមានទម្ងន់ធ្ងន់ពីរ-បីនាក់ទាញវាម្ដងមួយៗ ។ ប្ដូរខ្សែចេញនៅពេលវាចាប់ផ្ដើមចុះខ្សោយ ។

- ត្រូវធ្វើយ៉ាងណាឱ្យកុមារចូលរួមនៅក្នុងការរចនាប្លង់សាងសង់ ការសាងសង់និងថែទាំសួនលេងកំសាន្ត ។ កុមារអាចបំពេញការងារជាច្រើនដោយមានមនុស្សធំជួយណែនាំពួកគេ ។

